# កញ្ចប់ឧបករណ៍

ស្តង់ដារពិការភាពសំរាប់ការអប់រំ



# គាំទ្រអោយកូនអ្នកៈ នៅវ័យដំបូង

នេះជាកញ្ចប់ឧបករណ៍សំរាប់មាតាបិតានិងអ្នកថែរក្សាក្មេងដែលមាន ពិការភាព។ វាពន្យល់អំពីសិទ្ធិកូនរបស់អ្នកក្នុងសេវាថែទាំ និងអប់រំ កុមារភាពវ័យដំបូង (ECEC)និងពីរបៀបដែលអ្នកអាចគាំទ្រអោយកូនរបស់អ្នកក្នុង ECEC។

**ធនធាននេះត្រូវបានផ្តែដោយមាតាបិតានិងអ្នកថែរក្សាក្មេងដែលមានពិការភាព រួមនឹងនឹងជំនួយពីកុមារនិងក្មេងដែលមានពិការភាព អូស្ត្រាលី (Children and Yong People with Disability Australia - CYDA).**

## អំពីធនធាននេះ

ធនធាននេះត្រូវបានទទួលមូលនិធិពីរដ្ឋាភិបាលអូស្ត្រាលី។ វាត្រូវបានថ្លៃដោយមាតាបិតានិងអ្នកថែរក្សាក្មេងដែលមានពិការភាព រួមនឹងជំនួយពី**កុមារនិងយុវជនដែលមានពិការភាពអូស្ត្រាលី** (Children and Yong People with Disability Australia - CYDA)។

រដ្ឋាភិបាលអូស្ត្រាលីទទួលស្គាល់ម្ចាស់ទឹកដីដើមនិងអ្នកថែរក្សាប្រទេសទូទាំងប្រទេសអូស្ត្រាលី។ យើងទទួល ស្គាល់ដល់  ទំនាក់ទំនងដ៏និរន្តន៍ជាមួយដី ទឹក និងសហគមន៍របស់គេ។ យើងសូមគោរពដល់ពួកគេនិងដល់ ពួកចាស់ទុំពីអតីតកាលនិងបច្ចុប្បន្នកាល។ យើងសូមគោរពដល់ការអនុវត្តផ្នែកវប្បធម៌ ព្រលឹងវិញ្ញាណ និងការអប់រំនៃជនអាបូរិជិនល និងពួកកោះTorres Straight។

## កំណត់សំគាល់ពីភាសា

ធនធាននេះប្រើភាសាបុគ្គលមុន (ឧទាហរណ៍ ក្មេងដែលមានពិការភាព)។ ប៉ុន្តែវិធីនេះមិនសមនឹងមនុស្ស   គ្រប់រូប ហើយមនុស្សជាច្រើនចូលចិត្តភាសាអត្តសញ្ញាណមុន (ឧទាហរណ៍ ក្មេងពិការ)។

វាសំរេចទៅលើបុគ្គលម្នាក់ៗ ដែលគេជ្រើសរើសសំគាល់ខ្លួនដោយរបៀបណានោះ។ យើងសូមលើកទឹកចិត្តអ្នក អោយសួរគេថាគេចូលចិត្តអ្វី។ យើងក៏ទទួលស្គាល់ប្រវត្តិសាស្ត្រដ៏ជ្រាលជ្រៅដែលនៅពីក្រោយពាក្យទាំងនេះ។

ពាក្យ‘ការកែសំរួលសមហេតុសមផល’‘ការកែសំរួល’ឬ‘ការបំពេញបំណង’ ត្រូវបានគេប្រើសំដៅទៅលើន័យតែមួយ។យើងប្រើពាក្យទាំងនេះឆ្លះគ្នាក្នុងធនធាននេះ។     ‘ការកែសំរួលសមហេតុសមផលត្រូវបានប្រើក្នុង  ច្បាប់ *Disability Discrimination Act 1992*.

ធនធាននេះគឺសំរាប់មាតាបិតានិងអ្នកថែទាំ។យើងប្រើពាក្យកូនរបស់អ្នកគឺមានន័យថាកូនណាដែលអ្នករ៉ាប់ទទួលខុសត្រូវ។

## ធនធានបន្ថែម

នេះគឺមួយផ្នែកនៃធនធានមួយក្រុម។ អ្នកអាចរកឃើញនៅក្នុងវ៉ែបសៃត៍  នៃក្រសួងអប់រំ ឬដោយស្កេនកូដ QR.

ធនធាននេះក៏មាននៅក្នុង Easy Read, Auslan និងភាសាផ្សេងៗមួយចំនួនទៀត។អ្នកអាចចូលមើលសំណេរទាំងនោះនៅវ៉ែបសៃត៍ Australian Government Department of Education ឬ ដោយស្កេនកូដ QR

ស្កេនកូដ QR

***កំណត់សំគាល់មាតិកា:*** *កញ្ចប់ឧបករណ៍នេះមានគំរូនៃការមិនរាប់បញ្ចូល។ សំរាប់ជំនួយគាំទ្រ  សូមទូរស័ព្ទមក Lifeline តាមលេខ* ***13 11 14*** *ឬផ្ញើសារតាមលេខ* ***0477 13 11 14****.*

## កញ្ចប់ឧបករណ៍នេះសំរាប់អ្នកណា

កញ្ចប់ឧបករណ៍នេះគឺសំរាប់អ្នកបើអ្នកមានកូនដែលមានពិការភាព។ អ្នកប្រហែលជាឪពុកម្តាយឬអ្នកថែរក្សារបស់គេ។

## កញ្ចប់ឧបករណ៍នេះគឺសំរាប់អ្វី

កញ្ចប់ឧបករណ៍នេះគឺសំរាប់ជួយអ្នកអោយគាំទ្រកូនរបស់អ្នកក្នុងសេវាថែទាំនិងអប់រំកុមារភាពវ័យដំបូង (ECEC)។ នេះមានន័យថាមកនិយាយជាមួយសេវាកម្មECEC ដើម្បីធ្វើយ៉ាងណាអោយគេផ្តល់ការអប់រំ និងការថែទាំដែលកូនអ្នកមានសិទ្ធិទទួល។

ការគាំទ្រកូនអ្នកមានន័យថានិយាយជំនួសគេ។

សេវាកម្មECEC គឺមជ្ឈមណ្ឌលថែទាំពេញមួយថ្ងៃ សេវាថែទាំពេលថ្ងៃរបស់ក្រុមគ្រួសារ និងមត្តេយ្យសាលា។

សិទ្ធិសំរាប់កុមារដែលមានពិការភាពក្នុងECECជាសិទ្ធិតាមច្បាប់ក្រោមច្បាប់អូស្ត្រាលី។

គ្រួសារណាដែលប្រើសេវាថែទាំក្រៅពីម៉ោងសាលាប្រហែលជាជ្រាបថាធនធានេះមានសារៈប្រយោជន៍។

## កញ្ចប់ឧបករណ៍នេះនិយាយពីអ្វីខ្លះ

កញ្ចប់ឧបករណ៍នេះ:

- ផ្តល់ព័ត៌មាននិងគំនិតដើម្បីជួយអ្នកអោយធ្វើការគាំទ្រអោយកូនរបស់អ្នក
- ផ្តល់អ្នកនូវពាក្យសំខាន់ៗនិងពាក្យណែនាំមកប្រើនៅពេលនិយាយជាមួយសេវាកម្មECECC
- ពន្យល់ពីរបៀបសេវាកម្មECECអាចជួយកូនអ្នកចូលរួម ហើយនិងរៀន។

វានិយាយអំពី:


- ច្បាប់រើសអើងពិការភាពអូស្ត្រាលី(ទំព័រ ២)
- ច្បាប់ទាំងនេះមានន័យយ៉ាងណាសំរាប់កូនអ្នក (ទំព័រ ៤)
- សិទ្ធិនិងទំនួលខុសត្រូវ (ទំព័រ ៤)
- សំណួរដែលត្រូវសួរពេលប្រើសេវាកម្មECEC (ទំព័រ ៦)
- ព័ត៌មានបន្ថែមនិងជំនួយ (ទំព័រ ៧)

# ច្បាប់រើសអើងពិការភាពអូស្ត្រាលី

កុមារទាំងអស់ដែលមានពិការភាពក្នុងប្រទេសអូស្ត្រាលីត្រូវបានការពារដោយ *ច្បាប់រើសអើងពិការភាព 1992* (***Disability Discrimination Act 1992*** **)** **(DDA).**

កូនរបស់អ្នកត្រូវបានការពារដោយច្បាប់DDA នៅពេលគេទៅសេវាកម្មECECណាមួយ។
នេះរាប់បញ្ចូលមជ្ឈមណ្ឌលថែទាំពេញមួយថ្ងៃ សេវាថែទាំពេលថ្ងៃរបស់ក្រុមគ្រួសារ និងមត្តេយ្យសាលា។

## និយមន័យ: ច្បាប់រើសអើងពិការភាព1992

DDA ជាច្បាប់ដែលបានដល់មនុស្សគ្រប់រូបក្នុងអូស្ត្រាលី។ វាការពារមិនអោយមានការរើសអើងដោយសារគេមានពិការភាព។ នេះមានន័យថាគេមិនត្រូវទទួលការប្រព្រឹត្តអាក្រក់ជាងការដែលគេមិនមានពិការភាព។

មត្តេយ្យសាលាក៏ត្រូវបានការពារដោយ *ស្តង់ដារពិការភាពសំរាប់ការអប់រំ2005* **(*Disability Standards for Education 2005)*** (DSE)។ ស្តង់ដារ DSE ចែងអំពីអ្វីដែលសេវាកម្មទាំងនេះត្រូវធ្វើដើម្បីជួយគាំទ្រក្មេងដែលមានពិការភាព។ ស្តង់ដារ DSE មិនបង់ថ្លៃមើលថែទាំក្មេងទេ តែរដ្ឋាភិបាលអូស្ត្រាលីកំពុងពិនិត្យរកវិធីផ្លាស់ប្តូរ ការនេះ។

## និយមន័យ: ស្តង់ដារពិការភាពសំរាប់ការអប់រំ2005

DSE ជាច្បាប់មួយចំនួនដែលស្ថិតនៅក្រោម DDA. ច្បាប់ទាំងនោះបំភ្លឺកាតព្វកិច្ចរបស់អ្នកផ្តល់ការអប់រំ។
DSE ពន្យល់ពីសិទ្ធិរបស់សិស្សដែលមានពិការភាព និងអ្វីដែលអ្នកផ្តល់ការអប់រំត្រូវធ្វើដើម្បីគាំទ្រ និងការពារពួកគេ។

ក្រោមច្បាប់ DDA និង DSE កុមារដែលមានពិការភាពមានសិទ្ធិ:

- ទទួលការអប់រំនិងសេវាថែទាំដូចមិត្តភក្តិស្រករៗពួកគេ
- ទទួលការកែសំរួលសមហេតុផល
- ត្រូវបានការពារពីការបៀតបៀននិងការធ្វើអោយទៅជាជនរងគ្រោះ។ (សូមមើលធនធាននេះ ការបង្ការមិនអោយគេធ្វើបាបក្នុងការពន្យល់ស្តង់ដារពិការភាពសំរាប់ការអប់រំរបស់យើង ដើម្បីស្វែងយល់បន្ថែម)។

## និយមន័យ: ការកែសំរួលសមហេតុផល

ការកែសំរួលគឺជាការផ្លាស់ប្តូរឬការសំរប។ វាជាអំពើដែលគាំទ្រកុមារដែលមានពិការភាព ដើម្បីអោយគេប្រើសេវាECEC ដូចមិត្តភក្តិស្រករៗខ្លួនគេដែរ។ ការកែសំរួលនឹងជួយកុមារដែលមានពិការភាពអោយ  ចូលរួមដូចកុមារដែលគ្មានពិការភាព។

ការកែសំរួលអាចជាមនុស្ស សម្ភារៈ ឬការផ្លាស់ប្តូររបៀបធ្វើអ្វីមួយ។ បើការផ្លាស់ប្តូរវាសមហេតុផល ជា ទូទៅ សេវាកម្មECEC ត្រូវតែធ្វើវា។ គេនឹងមិនធ្វើការផ្លាស់ប្តូរដែលបង្កើតអោយមានភាពលំបាកដ៏គ្មានហេតុផលសំរាប់ពួកគេទេ។

## និយមន័យ: ភាពលំបាកមិនសមហេតុផល

ភាពលំបាកមិនសមហេតុផលគឺជាការកែសំរួលដ៏ច្រើនហួសសំរាប់សេវាកម្មនឹងធ្វើ។ ឧទាហរណ៍ ការកែសំរួលអាចថ្លៃពេក។

សេវាកម្មនឹងបង្ហាញថាការកែសំរួលនឹងបណ្តាលអោយមានភាពលំបាកមិនសមហេតុផល។ អ្នកថែទាំនិងក្រុមគ្រួសារពុំបាច់បង្ហាញអ្វីទេ។

ស្ថានភាពគ្រប់ផ្នែកនឹងត្រូវបានពិចារណាមើលនៅពេលសំរេចថាតើគួរប្រើការលើកលែងនេះឬអត់។
នេះរាប់បញ្ចូល:

- ផលវិបាកវិជ្ជមាន ឬអវិជ្ជមាននៃការផ្លាស់ប្តូរដល់អ្នកទាំងអស់ដែលពាក់ពិន (ឧ. កូនរបស់អ្នក សេវាកម្ម គ្រូ ឬកុមារដទៃទៀត)
- ផលវិបាកនៃពិការភាពដល់កូនរបស់អ្នក
- ស្ថានភាពថវិកានៃសេវាកម្ម (ឧ. បើសេវាកម្មមានថវិកាជំនួយឬជំនួយតាមទំរង់ផ្សេងទៀត - ឬតំលៃប្រមាណនៃការធ្វើការកែសំរួល)។

អ្នកអាចយល់ដឹងថែមទៀតក្នុងធនធាន
ការពន្យល់ស្តង់ដារពិការភាពសំរាប់ការអប់រំរបស់យើង។

# ច្បាប់ទាំងនេះមានន័យអ្វីខ្លះសំរាប់កូនអ្នក

កូនអ្នកដែលមានពិការភាពមានសិទ្ធិដូចកុមារដែលគ្មានពិការភាព គឺមានសិទ្ធិនឹង:

- ចុះឈ្មោះក្នុងសេវាកម្មECEC
- ចូលរួម និងរៀនក្នុងវិធីស្រដៀងនឹងមិត្តស្រករៗគ្នាដែរ។

They should have the same (or very similar) choices and opportunities.

# សិទ្ធិនិងទំនួលខុសត្រូវ

### *តើកូនអ្នកត្រូវការការវិនិច្ឆ័យរោគសំរាប់ច្បាប់DDA ឬDSE ដើម្បីដាក់ពាក្យសុំឬទេ?*

កូនអ្នកមិនត្រូវការការវិនិច្ឆ័យរោគសំរាប់ច្បាប់DDA ឬDSE ដើម្បីដាក់ពាក្យសុំឬទេ។
បើគិតថាកូនអ្នកត្រូវរស់នៅទាំងមានពិការភាព នោះអាចប្រើច្បាប់DDA និង DSE បាន។

បើកូនអ្នកមានពិការភាព សេវាECEC របស់គាត់ប្រហែលត្រូវការធ្វើការកែសំរួលសមហេតុផលដើម្បីគាំទ្រគាត់។ គេប្រហែលមិនត្រូវការភ័ស្តុតាងនៃការវិនិច្ឆ័យរោគដើម្បីយល់ស្របទៅនឹងការនេះទេ ប៉ុន្តែវាអាចជួយបើអាចផ្តល់សំបុត្រ (ឬលិខិតស្រដៀងគ្នា) ពីអ្នកមានវិជ្ជាជីវៈផ្នែកសុខភាព។ នេះនឹងជួយអោយសេវាកម្មដឹងថាកូនអ្នកត្រូវការការកែសំរួលអ្វីខ្លះ។

### *តើសេវាកម្មមានសិទ្ធិបដិសេធកូនខ្ញុំឬទេ?*

សេវាECEC ជាទូទៅ ពុំអាចបដិសេធកូនរបស់អ្នកទេ ដោយព្រោះគាត់មានពិការភាព។ កុមារដែលមានពិការភាពមានសិទ្ធិស្មើនឹងមិត្តស្រករគ្នាដើម្បី:

- ចុះឈ្មោះក្នុងសេវាECEC
- ចូលរួមក្នុងសេវាECEC។

សេវាECECមិនដាក់កំណត់ថាតើមានកូនដែលមានពិការភាពប៉ុន្មាននាក់ដែលគេត្រូវទទួលទេ។ ជាទូទៅ គេមិនអាចប្រើការខ្វះមូលនិធិជាមូលហេតុមកបដិសេធការចុះឈ្មោះទេ។ បើសេវាកម្មនោះមិនបានតាំងឡើងនា បច្ចុប្បន្នដើម្បីទ្រទ្រង់កូនរបស់អ្នកទេ នោះគេត្រូវធ្វើការផ្លាស់ប្តូរ លុះត្រាគេអាចបង្ហាញអោយឃើញថាមានការលើកលែង។ (សូមមើល ភាពលំបាកមិនសមហេតុផល (ទំព័រ ៣))។

### *តើខ្ញុំអាចសុំការកែសំរួលសមហេតុផលបានទេ?*

បាន! សេវាECEC គួរធ្វើការកែសំរួលសមហេតុផលសំរាប់កូនរបស់អ្នក។ គេគួរគាំទ្រកូនអ្នកអោយចូលរួម។ អ្នកអាចធ្វើសហការជាមួយគេដើម្បីស្វែងរកការកែសំរួលណាដែលគាំទ្រកូនអ្នកបានល្អបំផុត។

> ឧទាហរណ៍:
> ក្មេងម្នាក់ធ្វើការទាក់ទងដោយប្រើសៀវភៅ Pragmatic Organisation Dynamic Display (PODD). គ្រូរបស់គាត់រៀនពីរបៀបគាំទ្រគាត់អោយចេះប្រើវា។ នេះធ្វើអោយក្មេងនោះជំរាបនូវក្តី ត្រូវការរបស់គាត់ និងអ្វីដែលគាត់កំពុងគិត។

‘ការចូលរួម’ត្រូវតែចូលរួមមែនទែន ហើយមានន័យ។ គេគួររាប់បញ្ចូលកូនអ្នកក្នុងកម្មវិធីឬសកម្មភាពគ្រប់ផ្នែក។

> ឧទាហរណ៍:
> ក្មេងម្នាក់អង្គុយនៅបន្ទប់ជាមួយមិត្តស្រករគ្នា មើលគេលេងដុំប្លុក។ សកម្មភាពនេះត្រូវបានតាំងឡើងក្នុងរបៀបដែលបណ្ឈប់ក្មេងមិនអោយលេងនឹងគេដែរ។ នេះមិនរាប់ថាចូលរួមទេ។

### *តើខ្ញុំអាចសួរសេវាកម្មអោយជួយការងារថែទាំខ្លួនឯងរបស់កូនខ្ញុំ រួមទាំងការបរិភោគនិងការទៅបង្គន់បានឬទេ?*

បាន! វាជាទំរង់មួយនៃការកែសំរួល។

សេវាកម្មមួយអាចហៅការងារម្យ៉ាងខ្លះថា ‘ជួយគាំទ្រផ្នែកពេទ្យ’ - ឧទាហរណ៍
ការប្រើទុយោបញ្ចូកអាហារ ឬប្រដាប់ជួយដកដង្ហើម។
វាមិនមែនជាទង្វើមិនសមហេតុផលទេដែលសួរសេវាកម្មថាតើគេមានជំនួយគាំទ្រទាំងនេះឬអត់នោះ។ បើសេវាកម្មពុំអាចធ្វើបានទេ នោះគេត្រូវពន្យល់មូលហេតុ។

## ស្វែងរកថែមទៀត

បើចង់ដឹងថែមទៀតអំពីរបៀបក្មេងដែលមានពិការភាពត្រូវបានការពារក្រោមច្បាប់DDA ឬពីអ្វីដែលត្រូវធ្វើបើសេវាកម្មណាមួយមិនអាចបំពេញកាតព្វកិច្ចរបស់គេបាន នោះសូមឆែកមើលសេចក្តីណែនាំច្បាប់DDAនៃគណៈកម្មាធិការសិទ្ធិមនុស្សអូស្ត្រាលី។

# សំណួរដែលត្រូវសួរនៅពេលជ្រើសរើសសេវាECEC

ការគិតគូររកសេវាកម្មដែលធ្វើការល្អបំផុតសំរាប់កូនរបស់អ្នកគឺលំបាកបន្តិច។ យកល្អ គួរធ្វើបញ្ជីសំណួរមួយសំរាប់សួរសេវាកម្មនីមួយៗ - និងសួរខ្លួនឯង។

ឧទាហរណ៍:

- តើអាកប្បកិរិយានៃសេវាកម្មចំពោះភាពចំរុះ ភាពខុសគ្នា និងពិការភាពគឺយ៉ាងម៉េចដែរ?
- តើគេនឹងជួយគាំទ្រកូនខ្ញុំដោយរបៀបណា?
- តើគេនឹងជួយគាំទ្រក្រុមគ្រួសារខ្ញុំដោយរបៀបណា?
- តើអ្វីទៅជាតំលៃនិងជំនឿរបស់គេ? សេវាកម្មទាំងអស់នឹងមានចំឡើយទាំងនេះនៅក្នុង ‘សេចក្តីថ្លែងទស្សនៈ’។
- តើបុគ្គលិកអនុវត្តតាមតំលៃទាំងនេះក្នុងការងាររបស់គេដូចម្តេចខ្លះ?
- តើគេនឹងប្រស្រ័យជាមួយខ្ញុំដើម្បីអោយស្គាល់ យល់ដឹង និងជួយគាំទ្រកូនខ្ញុំដោយរបៀបណា?
- តើគេនឹងចាត់ចែងការកែសំរួលដោយរបៀបណា (បើត្រូវការ)?
- សំណួរផ្សេងទៀត:

ដើម្បីរកចំឡើយ អ្នកអាចមកជួបបុគ្គលិកពីសេវាកម្ម។ អ្នកក៏អាចមើលតាមអនឡាញ - ឧ. នៅបណ្តាញ សង្គម ឬតាមវ៉ែបសៃត៍នៃសេវាកម្ម។
អ្នកក៏អាចសួរមាតាបិតានិងអ្នកថៃទាំងទៀតៗ។

យកល្អអ្នកគួរគិតពីចំឡើយដ៏ល្អបំផុតដល់សំណួរនីមួយៗថាតើវានឹងទៅជាយ៉ាងម៉េចដែរ។ នេះនឹងផ្តល់អ្នកនូវគំនិតច្បាស់ជាងមុននូវប្រភេទសេវាកម្មដែលអ្នកកំពុងស្វែងរក។

## ព័ត៌មានបន្ថែមនិងជំនួយគាំទ្រ

- *ស្តង់ដារពិការភាពសំរាប់ការអប់រំ2005* (https://www.legislation.gov.au/Details/F2005L00767)
- *ច្បាប់រើសអើងពិការភាព1992* (https://www.legislation.gov.au/Details/C2018C00125)
- មជ្ឈមណ្ឌលពិការភាពអូស្ត្រាលី https://www.disabilityaustraliahub.com.au/) – បញ្ជីអង្គការពិការភាព
- ច្រកផ្លូវពិការភាព (https://disabilitygateway.gov.au/education/early-childhood) – តំណទៅសេវាកម្ម អ្នកគាំទ្រ និងព័ត៌មានអំពីការអប់រំកុមារភាពវ័យដំបូង
- Australian Government Department of Education (https://www.education.gov.au/early-childhood)
- ក្រសួងអប់រំរដ្ឋាភិបាលអូស្ត្រាលី (https://www.startingblocks.gov.au/)
- បណ្តាញចិញ្ចឹមកូន (https://www.raisingchildren.net.au) – ) ព័ត៌មានពីការចិញ្ចឹមកូន/ថែរក្សាកូន និងផនធាននានា។



www.education.gov.au/disability-standards-education-2005